**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០៣០ សហវ.អពដ

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលអនុវត្តប្រមូលពន្ធលើ មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៤

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជំរាបលោក-លោកស្រីដែលជាម្ចាស់យានយន្តគ្រប់ប្រភេទមេត្តាជ្រាបថា : ចាប់តាំងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាស លេខ ២២៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០០៤ និងសេចក្តីជូនដំណឹងលេខ ០១៤ សហវ.ពដ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០០៤ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៤ លោក-លោកស្រី ជាម្ចាស់យានយន្តគ្រប់ប្រភេទមួយចំនួន ប្រកបដោយស្មារតីភ្ញាក់រលឹកយកចិត្តទុកដាក់គោរពកាតព្វកិច្ចបង់ពន្ធយ៉ាងច្រើនកុះករជាបន្តបន្ទាប់ ។

ក្នុងគោលបំណងដើម្បីឱ្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៤ ទទួលបានលទ្ធផលល្អប្រសើរថែមទៀតនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរេចពន្យារពេលការប្រមូលពន្ធនេះរហូតដល់ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៤ ។

ចាប់ពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៤តទៅ អង្គភាពពន្ធដារនឹង**ធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដង ស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់** ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជឿជាក់ថាលោក-លោកស្រី ដែលជាម្ចាស់យានយន្ត ពិតជានឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អជាមិនខាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់សាខាពន្ធដារគ្រប់ខេត្ត-ក្រុង
- ឯកសារ.កាលប្បវត្តិ